# មេរៀនទី ២១: ពេត្រុសជួយឱ្យនាងតេប៊ីថារស់ឡើងវិញ

## កិច្ចការ ៩:៣៦-៤៣

**គោលបំណង៖** ព្រះធ្វើការតាមរយៈមនុស្ស។

**ខគម្ពីរចងចាំ៖ ភីលីព ២:១៣** *"ដ្បិតគឺជាព្រះហើយ ដែលបណ្តាលចិត្តអ្នករាល់គ្នា ឲ្យមានទាំងចំណង់ចង់ធ្វើ ហើយឲ្យបានប្រព្រឹត្តតាមបំណងព្រះហឫទ័យទ្រង់ដែរ។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

សូមគិតអំពីរបៀបដែលពេត្រុសបានធ្វើកំហុសជាច្រើនមុនការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវ កំហុសដ៏ធំបំផុតរបស់គាត់គឺការបដិសេធព្រះយេស៊ូវ បីដង មុនពេលព្រះយេស៊ូវត្រូវបានគេឆ្កាង។ ប៉ុន្តែព្រះមិនបានបោះបង់ចោលពេត្រុសឡើយ។ ទ្រង់មិនត្រឹមតែអត់ទោសឲ្យពេត្រុសប៉ុណ្ណោះទេ ប៉ុន្តែទ្រង់បានស្តារគាត់ ហើយពង្រឹងឲ្យគាត់មានសេចក្តីជំនឿឡើងវិញផងដែរ។ តើអ្នកមានអារម្មណ៍ថាធ្វើខុសអ្វីខ្លះ? សូមសារភាពអំពើបាបរបស់អ្នកចំពោះព្រះឥឡូវនេះ ហើយទទួលការប្រោសឲ្យជាយ៉ាងពេញលេញដូចជា ពេត្រុសដែរ។

**ចំរៀង៖** ១. ព្រះយើងជាព្រះអស្ចារ្យ ២. ខ្ញុំអាចធ្វើគ្រប់ការ ៣. ព្រះអង្គនៃយើងទ្រង់ខ្លាំងពូកែ

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត «ខ្នងទល់ខ្នង»**



១.ឱ្យកុមារស្វែងរកដៃគូដែលមានមាឌប្រហាក់ប្រហែលគ្នា
២.ឱ្យដៃគូអង្គុយទល់ខ្នងគ្នាទៅវិញទៅមក ដោយដាក់ដៃរបស់ពួកគេខ្វាស់គ្នា ដោយបញ្ឈរជង្គង់ទៅទន្ទឹមនឹងទ្រូងរបស់ពួកគេ។



៣. គោលបំណងនៃល្បែងនេះគឺ ឲ្យអ្នកលេងក្រោកឈរដោយមិនប្រើដៃពីរ។
៤. ព្រះជាម្ចាស់បានចាត់អ្នកដទៃឲ្យមកជួយអ្នក ដូចជាអ្វីដែលដៃគូរបស់អ្នកបានជួយអ្នក ឲ្យក្រោកឈរឡើង ដោយមិនបាច់ប្រើដៃដូច្នោះដែរ។ សូមគិតពីមនុស្សនៅជុំវិញខ្លួនអ្នក ដែលអាចត្រូវការជំនួយពីអ្នក!

**៤. ការណែនាំមេរៀន**

តើអ្នកណាខ្លះដែលព្រះបានចាត់មកដើម្បីជួយដល់ប្អូនៗនៅពេលមានបញ្ហា? ចុះគ្រូបង្រៀន គ្រូពេទ្យ គ្រូគង្វាល និងឪពុកម្តាយរបស់ប្អូនវិញ? ព្រះតែងតែធ្វើការតាមរយៈមនុស្សដើម្បីសម្រេចនូវគោលដៅរបស់ទ្រង់។ ព្រះមានអំណាចធ្វើគ្រប់យ៉ាងដោយអង្គទ្រង់ ប៉ុន្តែព្រះអង្គបានប្រើមនុស្សឲ្យធ្វើការ ពីព្រោះការនេះនឹងជួយឲ្យមនុស្សមានភាពរីកចម្រើនក្នុងសេចក្តីជំនឿ និងមានទំនាក់ទំនងល្អជាមួយនឹងព្រះ។ ថ្ងៃនេះ យើងនឹងរៀនអំពីមនុស្សម្នាក់ដែលព្រះធ្លាប់ប្រើដើម្បីជួយនារីម្នាក់ឱ្យរស់ឡើងវិញ!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

រឿងនៅព្រះគម្ពីររបស់យើងថ្ងៃនេះ គឺនិយាយអំពីស្រ្តីម្នាក់ឈ្មោះ តេប៊ីថា។ តេប៊ីថាជាស្រ្តីល្អណាស់។ ព្រះគម្ពីរបានចែងថា តេប៊ីថាតែងតែធ្វើអំពើល្អនិងជួយជនក្រីក្រ ជាពិសេសស្រ្តីមេម៉ាយ។ នាងជួយប្រជាជនក្រីក្រដោយការកាត់សម្លៀកបំពាក់សម្រាប់ពួកគេ។ ថ្ងៃមួយតេប៊ីថាបានធ្លាក់ខ្លួនឈឺហើយក៏ស្លាប់ទៅ។ មនុស្សទាំងអស់ដែលនាងធ្លាប់ជួយបានយំសោក ដោយសារតែការស្លាប់របស់នាង។ ពួកគេសោកស្តាយ ជាខ្លាំងក្នុងការបាត់បង់មិត្តភក្តិរបស់ពួកគេ ហើយថែមទាំងយកសម្លៀកបំពាក់ដែលតេប៊ីថា កាត់សម្រាប់ពួកគេមកជាមួយដែរ មនុស្សមួយចំនួនបានឮថា ពេត្រុសនៅក្នុងក្រុងក្បែរនោះ ដូច្នេះគេក៏ស្នើសុំឲ្យពេត្រុសមកចូលរួមដែរ។ ប្រជាជនបង្ហាញសម្លៀកបំពាក់ដល់ពេត្រុស ហើយប្រាប់គាត់ថា តេប៊ីថាជាមនុស្សពិសេសប៉ុណ្ណា។ ពេត្រុសបានសុំឲ្យមនុស្សទាំងអស់ចេញពីបន្ទប់។ ពេលគាត់នៅម្នាក់ឯងជាមួយតេប៊ីថា គាត់បានអធិស្ឋានពីព្រោះគាត់ត្រូវដឹងថា ព្រះចង់ប្រើគាត់ដោយរបៀបណា។ ពេត្រុសដឹងថាព្រះធ្វើការតាមរយៈមនុស្ស។

តាមរយៈការអធិស្ឋាន ពេត្រុសបានដឹងថា ព្រះចង់ប្រើគាត់ដើម្បីនាំឲ្យតេប៊ីថាមានជីវិតរស់ឡើងវិញ។ ដូច្នេះគាត់បានសំឡឹងទៅតេប៊ីថា ហើយនិយាយថា «តេប៊ីថាក្រោកឡើង»។ ពេលនោះតេប៊ីថាបើកភ្នែកដោយព្រះចេស្តាមកពីព្រះតាមរយៈការអធិស្ឋានរបស់ពេត្រុស ហើយនាងក៏បានរស់ឡើងវិញ! សាកស្រមៃមើលថា គ្រប់គ្នារំភើបប៉ុនណា? ពួកគេពិតជារីករាយដែលព្រះបានប្រើពេត្រុស ដើម្បីជួយឲ្យតេប៊ីថារស់ឡើងវិញ!

ផ្នែកមួយនៃផែនការរបស់ព្រះ គឺត្រូវឲ្យអ្នករាល់គ្នានឹងដឹងថា ព្រះយេស៊ូវជានរណា។ តើអ្នកដឹងទេថាមានមនុស្សមួយចំនួនដែលពឹងផ្អែកលើអ្នកដើម្បីឲ្យអ្នកប្រាប់ពួកគេអំពីព្រះយេស៊ូវ? ព្រះជ្រើសរើសយកមនុស្សដើម្បីធ្វើការទាំងនេះ។ ពេលយើងព្យាយាមធ្វើដូចជាព្រះយេស៊ូវ ហើយធ្វើអ្វីដែលទ្រង់ចង់ឲ្យយើងធ្វើគឺព្រះអង្គនឹងជួយយើងឲ្យធ្វើអំពើល្អ។ មនុស្សស្គាល់ព្រះកាន់តែច្រើននៅពេលពួកគេឃើញអំពើល្អរបស់យើង។ ថ្ងៃនេះសូមអធិស្ឋានទៅព្រះហើយទូលសុំទ្រង់ឲ្យប្រើអ្នក ដើម្បីជួយអ្នកដទៃឱ្យរៀនអំពីព្រះយេស៊ូវ!

## ៦. សំនួរពិភាក្សា

១. តើតេប៊ីថាជាមនុស្សបែបណា? *តែងតែធ្វើអំពើល្អ និងជួយជនក្រីក្រ*

២. តើមានអ្វីកើតឡើងចំពោះនាង? *នាងឈឺហើយស្លាប់*

៣. តើព្រះប្រើនរណាដើម្បីនាំតេប៊ីថាឲ្យរស់ឡើងវិញ? *ពេត្រុស*

៤. តើព្រះធ្លាប់ធ្វើការតាមរយៈអ្នកដើម្បីធ្វើអំពើល្អ និងជួយអ្នកដទៃដែរឬទេ? *ឱ្យកុមារឆ្លើយ*

៥. តើអ្នកអាចចែកចាយដំណឹងល្អអំពីព្រះយេស៊ូវដល់អ្នកណាខ្លះក្នុងជីវិតរបស់អ្នក? *ឱ្យកុមារឆ្លើយ*

## ៧. ល្បែងកំសាន្ត « ព្រះបានធ្វើការតាមរយៈមនុស្សផ្សេងៗ»

**សម្ភារៈដែលត្រូវការ៖** ស្ករគ្រាប់ ឬអាហារសំរ៉ន់មួយចំនួន

សូមស្តាប់ដោយយកចិត្តទុកដាក់ អំពីការពិពណ៌នាដែលព្រះបានធ្វើ តាមរយៈ មនុស្សមួយចំនួននៅក្នុងព្រះគម្ពីរ បើប្អូនដឹងថាមនុស្សទាំងនោះជាអ្នកណា សូមលើកដៃនិយាយឈ្មោះរបស់ពួកគេ។ បើប្អូនឆ្លើយត្រូវប្អូននឹង

ទទួលបានស្ករគ្រាប់មួយ!



១. ព្រះបានធ្វើការតាមរយៈបុគ្គលម្នាក់នេះ ដើម្បីធ្វើជាមាតារបស់ព្រះយេស៊ូវ - *ម៉ារា*
២. ព្រះបានធ្វើការតាមរយៈបុគ្គលម្នាក់នេះ ដើម្បីធ្វើជាបិតារបស់ព្រះយេស៊ូវ - *យ៉ូសែប*
៣. ព្រះបានធ្វើការតាមរយៈបុគ្គលម្នាក់នេះ ដើម្បីប្រោសតេប៊ីថាឲ្យរស់ឡើងវិញ- *ពេត្រុស*
៤. ព្រះបានធ្វើការតាមរយៈបុគ្គលម្នាក់នេះ ដើម្បីសរសេរសៀវភៅ ១៣ កណ្ឌ ក្នុងចំណោម ២៧ កណ្ឌនៃ ព្រះគម្ពីរសញ្ញាថ្មី - *ប៉ុល*
៥. ព្រះបានធ្វើការតាមរយៈបុគ្គលម្នាក់នេះ ដើម្បីសង់ទូកធំមួយមុនកើតមានទឹកជំនន់ - *ណូអេ*
៦ ព្រះបានធ្វើការតាមរយៈបុគ្គលម្នាក់នេះ ដើម្បីមានកូនប្រុសម្នាក់នៅពេលគាត់មានអាយុ១០០ឆ្នាំ - *អ័ប្រាហាំ*
៧. ព្រះបានធ្វើការតាមរយៈបុគ្គលម្នាក់នេះ ដើម្បីញែកសមុទ្រក្រហម - *លោកម៉ូសេ*
គ្រូអាចត្រៀមនូវសំណួរផ្សេងទៀតដើម្បីសួរទៅកាន់សិស្ស។

**៨. ខគម្ពីរចងចាំ** **ភីលីព ២:១៣**

**៩. សកម្មភាព** **«បេះដូងចម្រុះពណ៌»**

**សម្ភារៈដែលត្រូវការ៖** ការបិត ក្រដាសចម្រុះពណ៌ និងរូបបេះដូងនៅលើក្រដាស

***សូមមើលខាងក្រោមដើម្បីបោះពុម្ព***





១. ឱ្យក្រដាសមានបេះដូងទទេរទៅកុមារគ្រប់គ្នា។
២.ឱ្យកុមារម្នាក់ៗនូវក្រដាសពណ៌មួយសន្លឹក ដើម្បីឱ្យកុមារទាំងអស់មានក្រដាសពណ៌ខុសៗគ្នា។
៣.ពួកគេត្រូវបំពេញរូបបេះដូងរបស់ពួកគេជាមួយនឹងពណ៌ជាច្រើន តាមដែលអាចធ្វើទៅបាន។ ដើម្បីធ្វើបែបនេះបាន ពួកគាត់ត្រូវសុំឲ្យមិត្តភ័ក្តិហែកក្រដាសរបស់គេឲ្យគាត់ ហើយគាត់ត្រូវហែកក្រដាសរបស់ខ្លួន ដើម្បីចែកដល់អ្នកដទៃវិញដែរ។
៤. កុមារដែលមានបេះដូងចម្រុះពណ៌ច្រើនជាងគេបំផុតនឹងឈ្នះល្បែងនេះ។
៥. សូមចាំថា ព្រះធ្វើការតាមរយៈមនុស្ស។ យើងត្រូវតែត្រៀមខ្លួនជានិច្ច ដើម្បីអនុញ្ញាតឱ្យព្រះជាម្ចាស់ប្រើយើង ដើម្បីចែកចាយដំណឹងល្អរបស់ព្រះយេស៊ូវ និងដើម្បីជួយដល់អ្នកដទៃ!

**១០. ចម្រៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*



